ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy
№ ៤៨៥ [illegible]

រាជធានីភ្នំពេញ, ថ្ងៃទី១៤ ខែមិថុនា ឆ្នាំ ២០០៨

# អាជ្ញាប័ណ្ណស្វែងរុករក

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ។
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០១/០៩ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០១ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការគ្រប់គ្រង និង ការធ្វើអាជីវកម្មធនធានរ៉ែ ។
- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និង ប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។
- បានឃើញកិច្ចព្រមព្រៀងស្តីពីការសិក្សាស្រាវជ្រាវ និងការធ្វើអាជីវកម្មរ៉ែលោហៈនៅតំបន់ភ្នំរូអី ស្រុកកែវសីម៉ា ស្រុកសែនមនោរម្យ និងស្រុកពេជ្រាដា ខេត្តមណ្ឌលគិរី រវាង ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល និងក្រុមហ៊ុន MAXUM METALS PTY LTD ចុះថ្ងៃទី 12 JUN 2008 ។

## សម្រេច

**ប្រការ១:** អនុញ្ញាតអោយក្រុមហ៊ុន MAXUM METALS PTY LTD មានអាសយដ្ឋាននៅផ្ទះលេខ ១៩៣ BEo ផ្លូវ៦៣ សង្កាត់បឹងកេងកង ១ ខណ្ឌចំការមន រាជធានីភ្នំពេញ ធ្វើការសិក្សាស្រាវជ្រាវរ៉ែលោហៈនៅតំបន់ភ្នំរូអី ស្រុកកែវសីម៉ា ស្រុកសែនមនោរម្យ និងស្រុកពេជ្រាដា ខេត្តមណ្ឌលគិរី លើផ្ទៃដីទំហំ ២៩៥,៣៥ (ពីររយកៅសិបប្រាំក្បៀសសាមសិបប្រាំ) គីឡូម៉ែត្រក្រឡា ដែលមានកូអរដោណេដូចតទៅ :

| ចំណុច | អាប់ស៊ីស | អ័រដោនេ | ចំណុច | អាប់ស៊ីស | អ័រដោនេ |
|---|---|---|---|---|---|
| A | 7 48 000 | 14 02 000 | I | 7 14 000 | 13 80 000 |
| B | 7 52 000 | 14 02 000 | J | 7 19 000 | 13 80 000 |
| C | 7 52 000 | 13 84 500 | K | 7 19 000 | 13 84 000 |
| D | 7 25 500 | 13 84 500 | L | 7 23 000 | 13 84 000 |
| E | 7 25 500 | 13 76 000 | M | 7 23 000 | 13 88 000 |
| F | 7 16 800 | 13 76 000 | N | 7 38 000 | 13 88 000 |
| G | 7 16 800 | 13 69 000 | O | 7 38 000 | 13 92 500 |
| H | 7 14 000 | 13 69 000 | P | 7 48 000 | 13 92 500 |

<u>ប្រការ២:</u> ក្រុមហ៊ុនត្រូវដំណើរការសិក្សាស្រាវជ្រាវរ៉ែលើផ្ទៃដីដែលបានកំណត់ខាងលើ ដោយអនុវត្តទៅតាមផែនការឆ្នាំ និងកម្មវិធីការងាររបស់ខ្លួនដោយធានាអនុវត្តតាមបទដ្ឋានបច្ចេកទេសក្នុងការសិក្សាស្រាវជ្រាវរុករករ៉ែ ។

<u>ប្រការ៣:</u> អាជ្ញាប័ណ្ណនេះមានសុពលភាពរយៈពេល ០២(ពីរ)ឆ្នាំ គិតចាប់ពីថ្ងៃចុះហត្ថលេខា ។ មុនផុតកំណត់ ៣០ថ្ងៃ ក្រុមហ៊ុនត្រូវដាក់ពាក្យសុំអនុញ្ញាតធ្វើការសិក្សាស្រាវជ្រាវរ៉ែបន្តជាថ្មី ។

<u>ប្រការ៤:</u> ក្នុងករណីប្រព្រឹត្តល្មើសលើល័ក្ខខ័ណ្ឌនៃកិច្ចព្រមព្រៀងចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០០៨ អាជ្ញាប័ណ្ណនេះនឹងត្រូវដកហូត ឬត្រូវពិន័យទៅតាមច្បាប់ស្តីពីការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ ។

<u>ប្រការ៥:</u> អគ្គនាយកនៃអគ្គនាយកដ្ឋានធនធានរ៉ែ អគ្គាធិការនៃអគ្គាធិការដ្ឋាន ប្រធាននាយកដ្ឋានគណនេយ្យ-ហិរញ្ញវត្ថុ ប្រធាននាយកដ្ឋានរដ្ឋបាល ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល ខេត្តមណ្ឌលគិរី និង ប្រធានក្រុមហ៊ុន MAXUM METALS PTY LTD ត្រូវទទួលអនុវត្តអាជ្ញាប័ណ្ណនេះ តាមភារៈកិច្ចរៀង១ខ្លួន។

<u>ប្រការ៦:</u> អាជ្ញាប័ណ្ណនេះមានអនុភាពគតិយុត្តិចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

<u>**ចំលងជូន**</u>

-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងមហាផ្ទៃ
-ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
-ក្រសួងបរិស្ថាន
-ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
-សាលាខេត្តមណ្ឌលគិរី
-សាលាស្រុកសែនមនោរម្យ
-សាលាស្រុកកែវសីមា
-សាលាស្រុកពេជ្រាដា
-ដូចប្រការ៥ "ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ

ស៊ុយ_សែម